# ភិសជាតក




*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធឧក្កណ្ឋិតភិក្ខុ (ភិក្ខុអផ្សុកចង់សឹក) បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* ***អស្សំ គាំ រជតំ ជាតរូបំ*** *ដូច្នេះជាដើម ។*

*រឿងរ៉ាវបច្ចុប្បន្ននៃជាតកនឹងមានជាក់ច្បាស់ក្នុង**កុសជាតក** ។ គ្រានោះ ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតមែនឬ ។ ភិក្ខុនោះទូលថា ពិតមែនហើយ ព្រះអង្គ ។ ព្រះពុទ្ធត្រាស់ថា ព្រោះអាស្រ័យអ្វី បានអផ្សុក ។ លោកទូលថា បពិត្រព្រះអង្គដ៏ចម្រើនអើយ ព្រោះអាស្រ័យកិលេស ។ ព្រះភគវាត្រាស់ថា ម្នាលភិក្ខុ អ្នកបួសក្នុងនិយ្យានិកសាសនាដែលមានសភាពបែបនេះ ព្រោះហេតុអ្វី បានជាអ្នកអផ្សុកព្រោះអាស្រ័យ*

កិលេសចិញ្ចឹម ព្រាហ្មណបណ្ឌិតទាំងឡាយបួស ជាពាហិរបព្វជិត ក្នុងកាលព្រះពុទ្ធមិនកើតឡើង ប្រារព្ធវត្ថុកាមនិងកិលេសកាម បានធ្វើការស្បថឲ្យជាឧប្បជ្ជនកសញ្ញា ដូច្នេះហើយព្រះអង្គនាំអតីតនិទានមកថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ក្នុងកាលនោះ ព្រះពោធិសត្វកើតជាបុត្ររបស់ត្រកូលព្រាហ្មណមហាសាល ដែលមានទ្រព្យ ៨០ កោដិ ពពួកញាតិទាំងឡាយដាក់ឈ្មោះឲ្យថា **មហាកញ្ចនកុមារ** ។ លំដាប់នោះ ក្នុងកាលដែលមហាកញ្ចនកុមារចេះដើរ ក៏បុត្រសូម្បីដទៃកើត ពួកញាតិទាំងឡាយដាក់ឈ្មោះឲ្យបុត្រនោះថា **ឧបកញ្ចនកុមារ** ។ បុត្រទាំងឡាយ ៧ កើត តាមលំដាប់យ៉ាងនេះ ។ ចំណែកធីតាមួយដែលជាប្អូនគេបង្អស់នោះ ពួកញាតិដាក់ឲ្យឈ្មោះនាងថា **កញ្ចនទេវី** ។

មហាកញ្ចនកុមារកាលចម្រើនវ័យធំហើយ បានទៅរៀនសិល្បសាស្ត្រទាំងពួងពីនគរតក្កសិលាហើយត្រឡប់មក ។ លំដាប់នោះ មាតាបិតាប្រាថ្នានឹងចងមហាកញ្ចនកុមារនោះដោយចំណងផ្ទះ ទើបនិយាយថា យើងនឹងនាំទារិកាអំពីត្រកូលដែលមានជាតិស្មើគ្នារបស់ខ្លួនមកដល់អ្នក អ្នកចូរតាំងនៅក្នុងភេទជាឃរាវាស ។ មហាកញ្ចនកុមារពោលថា បពិត្រលោកឪពុកអ្នកម្តាយ ខ្ញុំមិនត្រូវការដោយឃរាវាស ព្រោះភពទាំង ៣ ប្រាកដដល់ខ្ញុំដូចជាភ័យដ៏ពន្លឹក ហាក់ដូចជាត្រូវភ្លើងឆេះ ព័ទ្ធព័ន្ធដូចជាពន្ធនាគារ ផ្គត់ផ្គង់ដូចជារបស់គួរខ្ពើម ហាក់ដូចជាផែនដីប្រឡាក់ដោយលាមក មេថុនធម្មគឺខ្ញុំមិនធ្លាប់ឃើញសូម្បីដោយយល់សប្តិ បុត្រទាំងឡាយដទៃរបស់លោកមាន សូមលោកឲ្យគេគ្រប់គ្រងផ្ទះចុះ ដូច្នេះហើយ កាលត្រូវអង្វររឿយៗ សូម្បីមាតាបិតាបញ្ជូនសម្លាញ់ទាំងឡាយឲ្យទៅជួយអង្វរ ក៏មហាកញ្ចនកុមារមិនប្រាថ្នាដែរ ។

លំដាប់នោះ សម្លាញ់ទាំងឡាយសួរមហាកញ្ចនកុមារថា ម្នាលសម្លាញ់ អ្នកប្រាថ្នាអ្វី ទើបមិនប្រាថ្នាបរិភោគកាម ។ មហាកញ្ចនកុមារប្រាប់អធ្យាស្រ័យនេក្ខម្មៈ ដល់សម្លាញ់ទាំងនោះ ។ មាតាបិតាស្តាប់ពាក្យនោះហើយ ក៏ទៅសូមបុត្រដ៏សេស សូម្បីបុត្រទាំងនោះ ក៏មិនប្រាថ្នាដែរ ។ សូម្បីតែនាងកញ្ចនទេវីក៏មិនប្រាថ្នាការគ្រប់គ្រងផ្ទះដូចគ្នា ។ ក្នុងកាលខាងក្រោយមក មាតាបិតាធ្វើកាលកិរិយាទៅ ។ មហាកញ្ចនបណ្ឌិតធ្វើកិច្ចគប្បីធ្វើដល់មាតាបិតាហើយ បានឲ្យមហាទានដល់មនុស្សកម្សត់ និងអ្នកដំណើរ ដោយទ្រព្យ ៨០ កោដិ នាំយកប្អូនប្រុសទាំង ៦ ប្អូនស្រី ១ ទាសៈ ១ ទាសី ១ និងសម្លាញ់ ១ ចេញទៅសាងមហាភិនេស្ក្រមណ៍ ចូលទៅកាន់ព្រៃហិមពាន្ត ។ ពួកគេទាំងឡាយនោះធ្វើអាស្រមនៅលើភូមិភាគគួរជាទីរីករាយ ដែលអាស្រ័យនៅជិតស្រះបទុមមួយ ក្នុងព្រៃហិមពាន្តនោះ ហើយនាំគ្នាបួស ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយមើមឈើ ផ្លែឈើក្នុងព្រៃជាអាហារ ។

ជនទាំងឡាយនោះ កាលទៅកាន់ព្រៃ ក៏ទៅជាមួយគ្នា អ្នកណាមួយឃើញផ្លែឈើ ឬស្លឹកឈើក្នុងទីណា តែងហៅសូម្បីជនដទៃ ឲ្យទៅក្នុងទីនោះ ម្នាក់ៗ និយាយពីវត្ថុដែលបានឃើញ និងឮជាដើម ហើយបេះ ហាក់ដូចជាកន្លែងធ្វើការរបស់អ្នកស្រុក ។ លំដាប់នោះ មហាកញ្ចនតាបសជាអាចារ្យគិតថា ការស្វែងរកផលាផល ដោយអំណាចសេចក្តីល្មោភយ៉ាងនេះ មិនសមគួរដល់យើងដែលជាអ្នកលះបង់ទ្រព្យ ៨០ កោដិ ហើយបួសឡើយ ចាប់ពីពេលនេះទៅ យើងនឹងនាំយកផលាផលតែម្នាក់ឯងប៉ុណ្ណោះ ។ មហាកញ្ចនតាបសនោះ ទៅដល់អាស្រមហើយ ក្នុងវេលាសាយណ្ហសម័យ បានហៅតាបសទាំងអស់មកប្រជុំគ្នា ប្រាប់សេចក្តីនោះ ហើយពោលថា អ្នកទាំងឡាយចូរធ្វើសមណធម៌ នៅក្នុងទីនេះចុះ យើងនឹងទៅនាំផលាផល ។ គ្រានោះ តាបសទាំងឡាយមានឧបកញ្ចនតាបសជាដើមពោលថា បពិត្រលោកអាចារ្យ ពួកយើងបួសដោយអាស្រ័យលោក លោកចូរធ្វើសមណធម៌ក្នុងទីនេះចុះ សូម្បីប្អូន

ស្រីរបស់យើងក៏ត្រូវនៅក្នុងទីនេះដែរ ចំណែកនាងទាសីក៏ចូរនៅក្នុងសម្នាក់ប្អូនស្រីចុះ ពួកយើងជាជន ៨ នាក់ នឹងនាំយកផលាផល ដោយវារៈវេន ចំណែកលោកទាំង ៣ ចូររួចផុតពីវេនចុះ ដូច្នេះហើយ នាំគ្នាកាន់យកបដិញ្ញា ។

ចាប់តាំងពីពេលនោះមក បណ្ដាជនទាំង ៨ នោះ ជនម្នាក់ៗ តែងទៅនាំយកផលាផលដោយវារៈនៃវេន ។ ជនដ៏សេស ក៏នៅក្នុងបណ្ណសាលារបស់ខ្លួនៗ ប៉ុណ្ណោះ មិនបាននៅជាមួយគ្នា ដោយមិនមែនហេតុឡើយ ។ អ្នកដែលដល់វារៈវេនហើយ ក៏នាំយកផលាផលមកហើយបែងចែកជា ១១ ចំណែកដាក់លើផែនថ្ម ដែលមានក្នុងទីនោះ ហើយវាយរគាំងជាសញ្ញា កាន់យកចំណែករបស់ខ្លួន ហើយចូលទៅកាន់លំនៅ ។ តាបសដ៏សេស ចេញមកដោយសញ្ញារគាំង មិនធ្វើសេចក្ដីលោភ ដើរទៅដោយរក្សាសេចក្ដីគោរព កាន់យកចំណែកដែលបែងចែកទុកដើម្បីខ្លួនហើយ ទៅកាន់លំនៅ បរិភោគ រួចធ្វើសមណធម៌ ។

ក្នុងកាលជាខាងក្រោយមក តាបសទាំងឡាយនោះ នាំយកក្រអៅឈូកមកបរិភោគ ជាអ្នកមានតបៈដ៏ក្ដៅ មានតបៈដ៏ខ្លាំងក្លា ជាអ្នកឈ្នះឥន្ទ្រិយដ៏ក្រៃលែង ធ្វើការបរិកម្មកសិណហើយរស់នៅ ។ លំដាប់នោះ ភពរបស់សក្កទេវរាជក៏កម្រើកញាប់ញ័រដោយតេជះសីលរបស់តាបសទាំងនោះ ។ ចំណែកស្ដេចសក្កៈកាលពិចារណា បានដឹងហេតុនោះហើយ ធ្វើសេចក្ដីរង្កៀសសង្ស័យថា ឥសីទាំងឡាយជារួចផុតចាកកាម ឬមិនទាន់ទេ ។ សក្កទេវរាជគិតថា យើងនឹងសាកល្បងឥសីទាំងឡាយនេះជាមុន ដូច្នេះហើយ បានញាំងចំណែករបស់ព្រះមហាសត្វឲ្យបាត់ទៅរហូត ៣ ថ្ងៃ ដោយអានុភាពរបស់ខ្លួន ។ ក្នុងថ្ងៃទី ១ ព្រះមហាសត្វមិនឃើញចំណែក គិតថា គេភ្លេចចំណែករបស់យើងហើយ, ក្នុងថ្ងៃទី ២ លោកគិតថា ទោសរបស់យើងនឹងគប្បីមាន បានជាគេមិនទុកចំណែករបស់យើង ដោយអំណាចការបណ្ដេញ, ក្នុងថ្ងៃទី ៣ គិតថា ព្រោះហេតុអ្វី បានជាគេមិនទុកចំណែករបស់យើង បើទោសរបស់យើង

មាន យើងឲ្យតាបសទាំងនោះអត់ទោស ដូច្នេះហើយ ក្នុងសាយណ្ហសម័យ លោកក៏ឲ្យសញ្ញារគាំង ។

តាបសទាំងអស់មកប្រជុំគ្នា ហើយពោលថា អ្នកឲ្យសញ្ញារគាំង ។ មហាកញ្ចនតាបសពោលថា ម្នាលអ្នកទាំងឡាយ គឺយើង ។ តាបសដ៏សេសសួរថា ព្រោះហេតុអ្វី លោកអាចារ្យ? ព្រះពោធិសត្វសួរថា នៃអ្នកទាំងឡាយ ក្នុងថ្ងៃទី៣ អ្នកណាជាអ្នកនាំផលាផលមក ? បណ្ដាតាបសទាំងនោះ តាបសមួយក្រោកឡើង ពោលថា គឺខ្ញុំ លោកអាចារ្យ យ៉ាងនេះហើយថ្វាយបង្គំ រួចឋិតនៅ ។ ព្រះពោធិសត្វសួរថា កាលអ្នកធ្វើការបែងចែកចំណែក មានបានធ្វើការបែងចែកចំណែកដល់យើងអត់ ។ តាបសនោះពោលថា បពិត្រលោកអាចារ្យ បានធ្វើហើយ ចំណែកដែលជាធំ ខ្ញុំបានធ្វើដល់លោក ។ ព្រះមហាសត្វសួរថា ចុះថ្ងៃម្សិលមិញ អ្នកជាអ្នកនាំយកក្រអៅឈូក ? តាបសដទៃមួយទៀត ក្រោកឡើងថ្វាយបង្គំហើយ ពោលថា គឺខ្ញុំ រួចឈរនៅ ។ មហាកញ្ចនតាបសសួរថា អ្នកកាលធ្វើការបែងចែក មានរលឹកដល់យើងអត់ ? តាបសនោះឆ្លើយថា ចំណែកដែលធំ គឺខ្ញុំបានទុកហើយដល់លោក ។ ព្រះពោធិសត្វសួរទៀតថា ចុះថ្ងៃនេះ អ្នកណាជាអ្នកនាំមក ? តាបសមួយរូបដទៃទៀតពោលថា គឺខ្ញុំ ហើយក្រោកឡើងថ្វាយបង្គំ រួចឈរនៅ ។ ព្រះមហាសត្វសួរថា កាលអ្នកធ្វើការបែងចែកក្រអៅឈូក បានរឭកដល់យើងអត់ ? តាបសនោះពោលថា ចំណែកដ៏ធំ គឺខ្ញុំបានធ្វើហើយដល់លោក ។

ព្រះមហាសត្វពោលថា ម្នាលអ្នកទាំងឡាយ ខ្ញុំមិនបានចំណែកក្រអៅឈូកអស់ ៣ ថ្ងៃ ទាំងថ្ងៃនេះផង ក្នុងថ្ងៃទី ១ ខ្ញុំមិនឃើញចំណែក ក៏គិតថា អ្នកបែងចែក ប្រហែលជាភ្លេច, ក្នុងថ្ងៃទី ២ យើងគិតថា ទោសយ៉ាងណានីមួយរបស់យើងនឹងមាន, ចំណែកថ្ងៃនេះ យើងគិតថា បើទោសរបស់យើងមាន យើងនឹងឲ្យអ្នកទាំងឡាយអត់ទោស ដូច្នេះទើបឲ្យអ្នកទាំងឡាយប្រជុំគ្នាដោយសញ្ញារគាំង ។ តាបសទាំងឡាយនោះនិយាយថា ពួកយើងធ្វើការ

បែងចែកចំណែកក្រអៅឈូកដល់លោកហើយ (មានតាបសមួយរូបពោលថា) ខ្ញុំមិនបាន យកទេ គួរដើម្បីនឹងដឹងអ្នកលួចបរិភោគក្រអៅឈូកទាំងនោះ ឈ្មោះថា ការលួចត្រឹមតែ ក្រអៅឈូក មិនសមគួរដល់អ្នកលះបង់កាម ហើយបួសឡើយ ។ តាបសទាំងឡាយនោះស្តាប់ ពាក្យនោះហើយ ម្នាក់ៗ ភ្ញាក់ផ្អើលថា កម្មនេះទាន់ហន់ណាស់ហ្ន៎ ។

សូម្បីទេវតាដែលកើតនៅនឹងដើមឈើធំមួយក្នុងព្រៃ ដែលនៅជិតអាស្រមនោះ ក៏ចុះ មកអង្គុយក្នុងសម្នាក់តាបសទាំងនោះ ។ មានដំរីមួយ កាលធ្វើការនាំការៈ មិនអាចទ្រាំនឹង សេចក្តីទុក្ខបាន ទើបទម្លាយគ្រឿងចំណង រត់ចូលក្នុងព្រៃ ហើយមកថ្វាយបង្គំពួកឥសីតាម កាលគួរ សូម្បីដំរីនោះ ក៏មកហើយឋិតនៅកន្លែងមួយ ។ នៅមានពានរមួយជាអ្នកលេង ជាមួយនឹងពស់ បានរួចផុតពីដៃហ្មពស់ រត់ចូលទៅក្នុងព្រៃ ហើយនៅជិតអាស្រមនោះដែរ ថ្ងៃនោះ សូម្បីពានរក៏មកថ្វាយបង្គំពួកឥសី រួចអង្គុយនៅកន្លែងមួយ ។

ស្តេចសក្កៈគិតថា យើងនឹងឃ្លាំមើលពួកឥសី ដូច្នេះក៏ជាសម្តែងខ្លួនជាអទិស្សមាន-កាយ (មានកាយមិនឲ្យគេឃើញ) ឋិតនៅក្នុងសម្នាក់របស់ឥសីទាំងនោះ ។ ក្នុងខណៈនោះ ឧបកញ្ចនតាបសដែលជាប្អូនរបស់ព្រះពោធិសត្វ ក្រោកឡើងចាកអាសនៈ ថ្វាយបង្គំព្រះ ពោធិសត្វ សម្តែងការរាប់អានតាបសដ៏សេស ហើយពោលថា បពិត្រលោកអាចារ្យ ខ្ញុំមិន ប្រាថ្នាវត្ថុដទៃឡើយ ខ្ញុំសូមបានការជម្រះខ្លួនប៉ុណ្ណោះ ។ ព្រះពោធិសត្វពោលថា អ្នកចូរបាន (ឱកាសពោល) ចុះ ។ ឧបកញ្ចនតាបសនោះ ឋិតនៅកណ្តាលពួកឥសី ពោលថា បើខ្ញុំ បរិភោគក្រអៅឈូករបស់លោក សូមឲ្យខ្ញុំជាយ៉ាងនេះចុះ ដូច្នេះហើយ កាលនឹងធ្វើការ សម្បថ ទើបពោលគាថាទី ១ថា

អស្សំ គវំ រជតំ ជាតរូបំ, ភរិយញ្ច សោ ឥធ លភតំ មជាបំ;
បុត្តេហិ ទារេហិ សមង្គី ហោតុ, ភិសានិ តេ ព្រាហ្មណ យោ អហាសិ។

*បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះចូរបាននូវសេះផង គោផង ប្រាក់ផង មាសផង ប្រពន្ធជាទីគាប់ចិត្ត ក្នុងលោកនេះផង ចូរនៅមូលមិត្តគ្នា ដោយកូននិងប្រពន្ធទាំងឡាយចុះ ។*

*បណ្ដាពាក្យទាំងនោះ ពាក្យថា **បាននូវសេះ គោផង** នេះ អ្នកសិក្សាគប្បីជ្រាបថា ឧបកញ្ចនតាបសពោលតិះដៀលវត្ថុកាមថា បិយវត្ថុមានប្រមាណប៉ុណ្ណា សេចក្ដីសោក និងទុក្ខមានប្រមាណប៉ុណ្ណោះ នឹងកើតឡើង ព្រោះការព្រាត់ប្រាស់ចាកបិយវត្ថុទាំងនោះ ។*

*ពួកឥសីស្ដាប់ពាក្យនោះហើយ ពោលថា ម្នាលមារិសៈ (អ្នកនិរទុក្ខ) លោកកុំពោលយ៉ាងនេះឡើយ សម្បថរបស់លោក ធ្ងន់ពេកណាស់ ដូច្នេះហើយ នាំគ្នា (យកដៃ) បិទត្រចៀក ។ សូម្បីព្រះពោធិសត្វក៏ពោលនឹងឧបកញ្ចនតាបសនោះថា ម្នាលប្អូន សម្បថរបស់អ្នក ធ្ងន់ពេកណាស់ អ្នកមិនបរិភោគ (ក្រអៅឈូករបស់ខ្ញុំ) ចូរអង្គុយលើអាសនៈដែលដល់អ្នកចុះ ។ កាលឧបកញ្ចនតាបសធ្វើការស្បថហើយអង្គុយចុះរួច ប្អូនទី ២ ក៏ក្រោកដោយរហ័ស ថ្វាយបង្គំព្រះមហាសត្វ កាលជម្រះនូវខ្លួនដោយសម្បថ ទើបពោលគាថាទី ២ ថា*

មាលញ្ច សោ កាសិកចន្ទនញ្ច, ធារេតុ បុត្តស្ស ពហូ ភវន្តុ;
កាមេសុ តិព្វំ កុរុតំ អបេក្ខំ, ភិសានិ តេ ព្រាហ្មណ យោ អហាសិ។

*បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះចូរទ្រទ្រង់នូវផ្កាកម្រងផង នូវសំពត់ដែលគេនាំមកអំពីដែនកាសីនិងខ្លឹមចន្ទន៍ផង ចូរឲ្យបុគ្គលនោះមានកូនច្រើនផង ចូរឲ្យ (បុគ្គលនោះ) ធ្វើនូវសេចក្ដីអាឡោះអាល័យដ៏ក្លៀវក្លា ក្នុងកាមទាំងឡាយផង ។*

*បណ្ដាពាក្យទាំងនោះ ពាក្យថា* ***ដ៏ខ្លាំងក្លា*** *សេចក្ដីថា ចូរធ្វើសេចក្ដីអាឡោះអាល័យដ៏ខ្លាំងក្លា ក្នុងវត្ថុកាម និងកិលេសកាមចុះ ។ ពាក្យនេះ តាបសទី ២ នោះ ពោលដោយអំណាចការហាមឃាត់សេចក្ដីទុក្ខថា បុគ្គលណាមានសេចក្ដីអាឡោះអាល័យដ៏ខ្លាំងក្លា ក្នុងវត្ថុកាម និងកិលេសកាម បុគ្គលនោះរមែងដល់សេចក្ដីទុក្ខដ៏ធំ ក្នុងកាលព្រាត់ប្រាសចាកវត្ថុកាមនិងកិលេសកាមនោះ ។*

*កាលតាបសទី ២ អង្គុយហើយ សូម្បីតាបសដ៏សេស ក៏បានពោលគាថានោះៗ តាមសមគួរដល់អធ្យាស្រ័យរបស់ខ្លួនៗ ថា*

**បហូតជញ្ញោ កសិមា យសស្សី, បុត្តេ គិហី ធនិមា សព្ពកាមេ;**
**វយំ អបស្សំ ឃរមាវសាតុ, ភិសានិ តេ ព្រាហ្មណ យោ អហាសិ។**

*(តាបសទី ៣ ស្បថថា)បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូក របស់លោក (បុគ្គលនោះ) ចូរមានស្រូវច្រើន មានកសិកម្ម មានយស (បាន) នូវកូនទាំងឡាយ ជាគ្រហស្ថ មានទ្រព្យ ចូរ (បាន) នូវកាមគ្រប់យ៉ាង ចូរកុំឲ្យឃើញនូវវ័យ (របស់ខ្លួន) នៅគ្រប់គ្រងចុះ ។*

**សោ ខត្តិយោ ហោតុ បសយ្ហការី, រាជាភិរាជា ពលវា យសស្សី;**
**ស ចាតុរន្តំ មហិមាវសាតុ, ភិសានិ តេ ព្រាហ្មណ យោ អហាសិ។**

*(តាបសទី ៤ ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះចូរបានជាក្សត្រ អ្នកធ្វើនូវការរឹបជាន់ ជារាជាធិរាជ មានពល មានយស ចូរបានគ្រប់គ្រងផែនដី ដែលមានសមុទ្រទាំង ៤ ជាទីបំផុតចុះ ។*

សោ ព្រាហ្មណោ ហោតុ អវីតរាគោ, មុហុត្តកស្មិំ បជេសុ យុត្តោ;
បូជេតុ ធំ រដ្ឋបតី យសស្សី, ភិសានិ តេ ព្រាហ្មណ យោ អហាសិ។

*(តាបសទី ៥ ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះចូរជាព្រាហ្មណ៍មិនប្រាសចាករាគៈ ចូរប្រកបក្នុងគន្ធក្បួនយាមនិងនក្ខត្តឫក្ស បុគ្គលជាម្ចាស់នៃដែន (ស្ដេច) ដែលមានយស ចូរបូជាព្រាហ្មណ៍នោះចុះ ។*

អជ្ឈាយកំ សព្ពសមន្តវេទំ, តបស្សិនំ មញ្ញតុ សព្ពលោកោ;
បូជេន្តុ នំ ជានបទា សមេច្ច, ភិសានិ តេ ព្រាហ្មណ យោ អហាសិ។

*(តាបសទី ៦ ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក លោកទាំងអស់ ចូរសំគាល់ (នូវបុគ្គលនោះ) ថាជាអ្នកស្វាធ្យាយនូវវេទ ព្រមទាំងមន្តគ្រប់យ៉ាង ថាជាអ្នកមានតបៈ ពួកអ្នកជនបទ ចូរឃើញហើយបូជានូវបុគ្គលនោះចុះ ។*

ចតុស្សទំ គាមវរំ សមិទ្ធំ, ទិន្នញ្ហិ សោ កុញ្ជតុ វាសវេន;
អវីតរាគោ មរណំ ឧបេតុ, ភិសានិ តេ ព្រាហ្មណ យោ អហាសិ។

*(តាបសជាសម្លាញ់ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរបរិភោគនូវស្រុកសួយដ៏ស្ដុកស្ដម្ភ ដែលកុះករដោយវត្ថុ ៤ យ៉ាង ហាក់ដូចស្ដេចវាសវៈប្រទានឲ្យ ចូរដល់នូវមរណៈ ទាំងមិនទាន់បានប្រាសចាករាគៈចុះ ។*

*ពាក្យថា ដែលកុះករដោយវត្ថុ ៤ យ៉ាង សេចក្ដីថា កុះករដោយមនុស្ស កុះករដោយធញ្ញជាតិ កុះករដោយឈើ និងកុះករដោយទឹក ។*

**សោ គាមណី ហោតុ សហាយមជ្ឈេ, នច្ចេហិ គីតេហិ បមោទមានោ;**
**សោ រាជតោ ព្យសន មាលត្ថ កិញ្ចិ, ភិសានិ តេ ព្រាហ្មណ យោ អហាសិ។**

*(តាបសជាខ្ញុំប្រុសស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះចូរបានជាធំក្នុងស្រុក ចូររីករាយ ដោយការរាំ និងច្រៀងទាំងឡាយក្នុងកណ្តាលនៃសម្លាញ់ កុំឲ្យបាននូវសេចក្តីវិនាសតិចតួចអំពីស្តេចឡើយ ។*

**យំ ឯករាជា បឋវឹ វិជេត្វា, ឥត្ថីសហស្សាន ឋបេតុ អគ្គំ;**
**សីមន្តិនីនំ បវរា កវាតុ, ភិសានិ តេ ព្រាហ្មណ យា អហាសិ។**

*(នាងកញ្ញនទេវីស្បថថា) បពិត្រព្រាហ្មណ៍ ស្រីណាលួចក្រអៅឈូកទាំងឡាយរបស់លោក សូមឲ្យស្តេចឯករាជដែលទ្រង់ឈ្នះនូវផែនដីលើកតម្កើង (ស្រីនោះ) ឲ្យប្រសើរលើសជាងស្រីទាំងមួយពាន់ សូមឲ្យ (ស្រីនោះ) បានជាស្រីប្រសើរលើសជាងស្រីទាំងឡាយចុះ ។*

*ពាក្យថា* ***ឲ្យប្រសើរលើសជាងស្រីទាំងមួយពាន់*** *សេចក្តីថា លោកពោលដោយអំណាចសេចក្តីស្អាតនៃពាក្យពោលប៉ុណ្ណោះ អធិប្បាយថា សូមឲ្យព្រះរាជាតែងតាំងស្រីនោះទុកក្នុងតំណែងដ៏ប្រសើរលើសជាងស្ត្រី ១៦០០០ នាក់ ។*

**ឥសីនញ្ហិ សា សព្ពសមាគតានំ, កុញ្ជេយ្យ សាទុំ អវិកម្បមានា;**
**ចរាតុ លាកេន វិកត្ថមានា, ភិសានិ តេ ព្រាហ្មណ យា អហាសិ។**

*(នាងទាសីស្បថថា) បពិត្រព្រហ្មណ៍ ទាសីណាលួចក្រអៅឈូកទាំងឡាយរបស់លោក ក៏បណ្តាទាសីទាំងឡាយ ទាសីនោះចូរកុំញាប់ញ័រ (ក្នុងកណ្តាល) នៃម្ចាស់ទាំងឡាយដែលជួបជុំគ្នាទាំងអស់ ចូរបរិភោគនូវវត្ថុមានរសឆ្ងាញ់ (ទាសីនោះ) ចូរប្រព្រឹត្តនិយាយកុហក ព្រោះហេតុតែលោកចុះ ។*

**អាវាសិកោ ហោតុ មហាវិហារេ, នវកម្មិកោ ហោតុ គជង្គលាយំ;**
**អាលោកសន្ធិំ ទិវសំ ករោតុ, ភិសានិ តេ ព្រាហ្មណ យោ អហាសិ។**

*(ទេវតាស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយ របស់លោក (បុគ្គលនោះ) ចូរបានជាចៅអាវាសក្នុងមហាវិហារចុះ ចូរជាអ្នកប្រកបដោយនវកម្មក្នុងនគរគជង្គលៈ ចូរធ្វើនូវបង្អួចឲ្យហើយតែមួយថ្ងៃចុះ ។*

*ពាក្យថា **ចៅអាវាស** ក្នុងគាថាដែលទេវតាពោលនោះ បានដល់ អ្នកគ្រប់គ្រងអាវាស (ព្រះចៅអធិការវត្ត) ។ ពាក្យថា **គជង្គលៈ** បានដល់ នគរដែលមានឈ្មោះយ៉ាងនោះ ។ បានឮថា ក្នុងគជង្គលនគរនោះ មានទព្វសម្ភារៈរកបានងាយ ។ បានឮមកថា ទេវបុត្រនោះ ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធកស្សបៈ លោកជាអាវាសិកសង្ឃត្ថេរក្នុងមហាវិហារចាស់មួយ ដែលមានទំហំមួយយោជន៍ អាស្រ័យនឹងគជង្គលនគរនោះ កាលលោកធ្វើនវកម្ម (ការសាងសង់) វិហារចាស់ រមែងសោយសេចក្តីទុក្ខលំបាកដ៏ធំ ។ ព្រោះហេតុនោះ ទេវបុត្រប្រារព្ធសេចក្តីទុក្ខនោះ ទើបពោលយ៉ាងនោះ ។*

**សោ ពជ្ឈតូ បាសសតេហិ ឆព្ភិ, រម្មា វនា និយ្យតុ រាជធានឹ;**
**តុត្តេហិ សោ ហញ្ញតុ បាចនេហិ, ភិសានិ តេ ព្រាហ្មណ យោ អហាសិ។**

*(ដំរីស្បថថា) បពិត្រព្រាហ្មណ៍ ដំរីណាលួចក្រអៅឈូកទាំងឡាយរបស់លោក ដំរីនោះ ចូរជាប់ដោយអន្ទាក់ច្រើន ត្រង់កន្លែងទាំង ៦ (គឺជើង ទាំង ៤ ក និង ចង្កេះ) ចូរឲ្យគេនាំអំពីព្រៃជាទីរីករាយទៅកាន់រាជធានីចុះ ដំរីនោះចូរឲ្យគេចាក់ដោយកង្វេរទាំងឡាយ ដែលមានដងវែង មានបន្ទាពីរចុះ ។*

**អលត្ថមាលី តិបុកណ្ណវិទ្ធា, លទ្ធីហតោ សប្បមុខំ ឧបេតុ;**
**សកច្ចពន្ធោ វិសិខំ ចរាតុ,ភិសានិ តេ ព្រាហ្មណ យោ អហាសិ។**

*(ស្វាស្បថថា) បពិត្រព្រាហ្មណ៍ ស្វាណាលួចក្រអៅឈូកទាំងឡាយ របស់លោក (ស្វានោះ) ចូរមានប្រឡៅក ហើយគេចោះត្រចៀកបំពាក់សំណរចុះ ឲ្យហ្មពស់វាយដោយរំពាត់ ហើយចូរទៅរកមាត់ពស់ចុះ ឲ្យគេចងយ៉ាងមាំ ហើយដើរទៅកាន់ច្រកល្ហកចុះ ។*

*កាលជនទាំង ១៣ ធ្វើការស្បថយ៉ាងនេះហើយ ព្រះមហាសត្វគិតថា មានអ្នកខ្លះនឹងគប្បីសង្ស័យក្នុងយើងថា តាបសនេះនិយាយដល់វត្ថុដែលមិនបាត់ថាបាត់ ដូច្នេះសូម្បីយើងក៏ត្រូវធ្វើការស្បថ ។ លំដាប់នោះ កាលធ្វើការស្បថ ទើបពោលគាថាទី ១៤ ថា*

**យោ វេ អនដ្ឋំវ នដ្ឋន្តិ ចាហ, កាមេវ សោ លភតំ ភុញ្ជតញ្ច;**
**អគារមជ្ឈេ មរណំ ឧបេតុ, យោ វា ភោន្តោ សង្កតិ កញ្ចិទេវ។**

***នៃអ្នកដ៏ចម្រើនទាំងឡាយ បុគ្គលណា ពោលនូវចំណែកដែលមិនបាត់ថាបាត់ ម្យ៉ាងទៀត បុគ្គលណារង្កៀសបន្តិចបន្តួច (ចំពោះអ្នកទាំងឡាយ) បុគ្គលនោះ ចូរបាន នឹងចូរបរិភោគនូវកាមទាំងឡាយចុះ ចូរស្លាប់ក្នុងកណ្តាលនៃផ្ទះចុះ ។***

*ពាក្យថា **នៃអ្នកដ៏ចម្រើនទាំងឡាយ** នេះ ជាពាក្យសម្រាប់ហៅ ។ លោកពោលអធិប្បាយថា នៃអ្នកដ៏ចម្រើនទាំងឡាយ អ្នកណាពោលដល់ចំណែកដែលមិនបាត់ថា បាត់ ឬអ្នកណារង្កៀសយ៉ាងណាមួយក្នុងអ្នកទាំងឡាយ អ្នកនោះចូរបានកាមគុណ ៥ ហើយបរិភោគកាមគុណចុះ ចូរកុំបានបួសដែលគួររីករាយ ចូរត្រេកអរនៅកណ្តាលអគារចុះ ។*

*កាលឥសីទាំងឡាយធ្វើការស្បថយ៉ាងនេះហើយ ស្តេចសក្កៈក៏ភិតភ័យ ហើយគិតថា យើងកាលសាកល្បងឥសីទាំងនេះ បានធ្វើក្រអៅឈូកឲ្យបាត់ទៅ, តាបសទាំងនេះតិះដៀល*

*កាម ហាក់ដូចជាលះបង់ដុំទឹកមាត់ នាំគ្នាធ្វើការស្បថ យើងនឹងសួរហេតុនៃការតិះដៀលកាម ដល់ឥសីទាំងនោះ ដូច្នេះហើយ សម្ដែងរូបឲ្យប្រាកដ ទៅថ្វាយបង្គំព្រះពោធិសត្វ កាលសួរ ទើបពោលគាថាបន្ទាប់ថា*

**យេនេសមាជា វិចរន្តិ លោកេ, ឥដ្ឋា កន្តា ពហូនមេតំ;**
**បិយំ មនុញ្ញំ ចិធ ជីវលោកេ, កស្មា ឥសយោ នប្បសំសន្តិ កាមេ។**

*(សត្វទាំងឡាយ) រមែងស្វែងរកនូវវត្ថុកាម និងកិលេសកាមណា ហើយត្រាច់ទៅក្នុងលោក វត្ថុកាមនិងកិលេសកាមនុ៎ះ ជាទីពេញចិត្តរបស់ទេវតានិងមនុស្សច្រើនគ្នា ក្នុងជីវ-លោកនេះ ចុះហេតុអ្វី ក៏ពួកឥសីមិនសរសើរនូវកាមទាំងឡាយ ។*

*ពាក្យថា **រមែងស្វែងរក** សេចក្ដីថា សត្វទាំងឡាយកាលស្វែងរកវត្ថុកាម និងកិលេស-កាម ដោយកម្មដែលសមគួរនិងមិនសមគួរ មានកសិកម្មគោរក្ខកម្មជាដើម តែងប្រព្រឹត្តទៅក្នុងលោក កាមនោះជារបស់គួរប្រាថ្នា គួរពេញចិត្ត គួរស្រឡាញ់ និងជាទីរីករាយនៃចិត្តរបស់សត្វជាច្រើន គឺជារបស់ពួកទេវតា និងមនុស្ស ព្រោះហេតុអ្វី ឥសីទាំងឡាយមិនសរសើរកាមទាំងឡាយចឹង ។*

*លំដាប់នោះ ព្រះមហាសត្វកាលវិសជ្ជនាបញ្ហា ទើបពោល ២ គាថា ថា*

**កាមេសុ វេ ហញ្ញរេ ពជ្ឈរេ ច, កាមេសុ ទុក្ខញ្ច ភយញ្ច ជាតំ;**
**កាមេសុ ភូតាធិបតី បមត្តា, បាបានិ កម្មានិ ករោន្តិ មោហា។**

*ជនទាំងឡាយ ត្រូវគេវាយ ត្រូវគេចង ព្រោះតែកាមទាំងឡាយ សេចក្ដីទុក្ខផង ភ័យផង ដែលកើតឡើងក៏ព្រោះតែកាមទាំងឡាយ បពិត្រព្រះភូតាធិបតី សត្វទាំងឡាយស្រវឹង ព្រោះកាមទាំងឡាយ ធ្វើនូវអំពើទាំងឡាយដ៏លាមក ព្រោះវង្វេង ។*

**តេ ចាបធម្មា បសវេត្វា ចាបំ, កាយស្ស ភេទា និរយំ វជន្តិ;**
**អាទីនវំ កាមគុណេសុ ទិស្វា, តស្មា ឥសយោ នប្បសំសន្តិ កាមេ។**

*ជនមានធម៌ដ៏លាមកទាំងឡាយនោះទទួលនូវបាប លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ព្រោះហេតុនោះ បានជាពួកឥសីមិនសរសើរនូវកាមទាំងឡាយ ព្រោះឃើញទោសក្នុងកាមគុណទាំងឡាយ ។*

*ពាក្យថា **ព្រោះតែកាមទាំងឡាយ** សេចក្តីថា បុគ្គលទាំងឡាយរមែងធ្វើទុច្ចរិតទាំងឡាយមានកាយទុច្ចរិតជាដើម ព្រោះអាស្រ័យកាម គឺមានកាមជាហេតុ ។ ពាក្យថា **ត្រូវគេវាយ** សេចក្តីថា រមែងត្រូវគេវាយដោយដំបងជាដើម។ ពាក្យថា **ត្រូវគេចង** សេចក្តីថា រមែងត្រូវគេចងដោយគ្រឿងចំណងមានខ្សែជាដើម ។ ពាក្យថា **សេចក្តីទុក្ខ** បានដល់កាយិកទុក្ខ និងចេតសិកទុក្ខ ដែលមិនដាច់ ។ ពាក្យថា **ភ័យ** បានដល់ភ័យសូម្បីទាំងអស់ មានអត្តានុវាទភ័យ (ភ័យពីការតិះដៀលខ្លួនឯង) ជាដើម ។ ពាក្យថា **ព្រះភូតាធីបតី** ជាពាក្យហៅសក្កទេវរាជ ។ ពាក្យថា **ទោស** បានដល់ ទោសមានសភាពបែបនោះ ។ ក៏ឯទោសក្នុងកាមទាំងឡាយនោះ អ្នកសិក្សាគប្បីសម្តែងដោយព្រះសូត្រទាំងឡាយ មានទុក្ខក្ខន្ធសូត្រជាដើម ។*

*ស្តេចសក្កៈស្តាប់ពាក្យរបស់ព្រះមហាសត្វហើយ មានចិត្តតក់ស្លុត ពោលគាថាបន្ទាប់ថា*

**វីមំសមានោ ឥសិនោ ភិសានិ, តីរេ គហេត្វាន ថលេ និធេសិំ;**
**សុទ្ធា អបាបា ឥសយោ វសន្តិ, ឯតានិ តេ ព្រហ្មចារី ភិសានិ។**

*ខ្ញុំល្បងមើលទេ ខ្ញុំយកក្រអៅឈូកទាំងឡាយរបស់ឥសី ក្បែរឆ្នេរទៅកប់ទុកលើគោក (ឥឡូវនេះ ខ្ញុំដឹងហើយថា) ឥសីទាំងឡាយ ជាអ្នកបរិសុទ្ធ មិនមានបាប បពិត្រលោកជាព្រហ្មចារី នុ៎ះក្រអៅឈូកទាំងឡាយរបស់លោក ។*

*ព្រះពោធិសត្វស្តាប់ពាក្យនោះហើយ ក៏ពោលគាថាថា*

ន តេ ជដា នោ បន កីឡនេយ្យា, ន ពន្ធវា នោ បន តេ សហាយា;
កិស្មិំ វុបត្ថម្ភ សហស្សនេត្ត, ឥសីហិ ត្វំ កីឡសិ ទេវរាជ។

*ម្នាលទេវរាជ ជាសហស្សនេត្ត (ពួកយើង) មិនមែនជាអ្នករបាំរបស់អ្នកទេ ទាំងមិនមែនជាសម្លាញ់របស់អ្នកទេ ហេតុអ្វីក៏អ្នក (ធ្វើ) នូវសេចក្តីមើលងាយចំពោះបុគ្គលដទៃ ហើយលេងជាមួយពួកឥសី ។*

*ពាក្យថា (ពួកយើង)* **មិនមែនជាអ្នករបាំរបស់អ្នកទេ** *សេចក្តីថា នៃទេវរាជ ពួកយើងមិនមែនជាអ្នករបាំ ជាអ្នកប្រកបដោយការលេង ឬជាអ្វីមួយរបស់ព្រះអង្គទេ ពួកយើងមិនមែនសូម្បីជាញាតិ ឬសម្លាញ់របស់ព្រះអង្គដែរ កាលបើយ៉ាងនោះ ព្រោះហេតុអ្វី ព្រះអង្គធ្វើការមើលងាយ ព្រោះអាស្រ័យអ្វី ព្រះអង្គទើបលលេងនឹងឥសីទាំងឡាយចឹង ។*

*លំដាប់នោះ សក្កទេវរាជ កាលសូមខមាទោស ទើបពោលគាថាទី ២០ ថា*

អាចរិយោ មេសិ បិតា ច មយ្ហំ, ឯសា បតិដ្ឋា ខលិតស្ស ព្រហ្មេ;
ឯកាបរាធំ ខម ភូរិបញ្ញ, ន បណ្ឌិតា កោធពលា ភវន្តិ។

*បពិត្រតាបសដ៏ប្រសើរ លោកម្ចាស់ជាអាចារ្យរបស់ខ្ញុំផង ជាបិតារបស់ខ្ញុំផង ម្ទប់ព្រះបាទរបស់លោកម្ចាស់នេះ សូមជាទីពឹង (របស់ខ្ញុំ) ដែលមានសេចក្តីភ្លាំងភ្លាត់ហើយ បពិត្រតាបស មានប្រាជ្ញាដូចជាផែនដី សូមលោកម្ចាស់អត់នូវកំហុសម្តង បណ្ឌិតទាំងឡាយមិនមានសេចក្តីក្រោធជាកម្លាំងទេ ។*

*លំដាប់នោះ ព្រះមហាសត្វក៏អត់ទោសដល់សក្កទេវរាជ កាលនឹងឲ្យពួកឥសីអត់ទោសឲ្យដោយខ្លួនឯង ទើបពោលគាថាដទៃថា*

**សុវាសិតំ ឥសិនំ ឯករត្តំ, យំ វាសវំ ភូតបតិទ្ទសាម;**
**សព្វេវ ភោន្តោ សុមនា ភវន្តុ, យំ ព្រាហ្មណោ បច្ចុទាទី ភិសានិ។**

*កាលដែលពួកឥសី (នៅក្នុងព្រៃ) សូម្បីតែមួយយប់ ក៏ឈ្មោះថា បាននៅល្អហើយ ព្រោះថាយើងទាំងឡាយបានជួបនឹងព្រះវាសវៈ ជាម្ចាស់នៃទេវតា ពួកអ្នកដ៏ចម្រើនទាំងអស់គ្នា ចូរតាំងចិត្តឲ្យល្អចុះ ត្បិតព្រាហ្មណ៍ (ជាអាចារ្យរបស់អ្នកទាំងឡាយ)បាននូវក្រអៅឈូកវិញហើយ ។*

*ស្ដេចសក្កៈថ្វាយបង្គំពួកឥសីហើយ ក៏ទៅកាន់ទេវលោកវិញ ។ ចំណែកពួកឥសី (ក្នុងកាលជាខាងក្រោយមក) បានញុំាងឈាន និងអភិញ្ញាឲ្យកើតឡើង ក៏ជាអ្នកទៅកាន់ព្រហ្មលោក ។*

*ព្រះសាស្ដានាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលភិក្ខុ បោរាណបណ្ឌិតទាំងឡាយធ្វើការស្បថហើយលះបង់កិលេស ដូច្នេះហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលជាទីបញ្ចប់នៃសច្ចៈ ឧក្កណ្ឋិតភិក្ខុបានតាំងនៅក្នុងសោតាបត្តិផល ។ ព្រះអង្គកាលប្រជុំជាតក ក៏ត្រាស់ព្រះគាថា ៣ ទៀតថា*

**អហញ្ច សារិបុត្តោ ច, មោគ្គល្លានោ ច កស្សបោ;**
**អនុរុទ្ធោ បុណ្ណោ អានន្ទោ, តទាសុំ សត្ត ភាតរោ។**

*បងប្អូនប្រុសប្រាំពីរនាក់ក្នុងកាលនោះគឺ តថាគត ១ សារីបុត្ត ១ មោគ្គល្លាន ១ កស្សបៈ ១ អនុរុទ្ធ ១ បុណ្ណៈ ១ អានន្ទ ១ ។*

កកិដ្ឋី ឧប្បលវណ្ណា ច, ទាសី ខុជ្ជុត្តរា តទា;
ចិត្តោ គហបតិ ទាសោ, យក្ខោ សាតាគិរោ តទា។

*ក្នុងកាលនោះ ប្អូនស្រីគឺនាងឧប្បលវណ្ណា ក្នុងកាលនោះ ទាសីគឺនាងខុជ្ជុត្តរា ខ្ញុំប្រុសគឺគហបតិឈ្មោះចិត្តៈ ក្នុងកាលនោះ ទេវតា គឺសាតាគិរយក្ខ ។*

ចាលិលេយ្យោ តទា ជាតោ, មធុរោ សេដ្ឋវារណោ;
កាឡុទាយី តទា សក្កោ, ឯវំ ធារេថ ជាតកំ។

*ក្នុងកាលនោះ ដំរីដ៏ប្រសើរ គឺដំរីឈ្មោះបាលិលេយ្យ ស្វាដ៏ប្រសើរ គឺមធុរៈ ក្នុងកាលនោះ ទេវរាជឈ្មោះសក្កៈ គឺកាឡុទាយី អ្នកទាំងឡាយចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។*

*ចប់ ភិសជាតក ។*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក បកិណ្ណកនិបាត បិដលេក ៦០ ទំព័រ ១៧)*

*ថ្ងៃសៅរ៍ ៤ កើត ខែមឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ១៦ ខែ មិថុនា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ.*